ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០១-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៤៣០ ស្តីពី ការដំឡើងឋានន្តរស័ក្តិ នាយនគរបាល ថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ចំនួន ០៣ រូប ៤៤៤៤

០១-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៤៣១ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាតិជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៤៤៤៥

០១-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៤៣២ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **នាត់ ឌីឡេន** នាយនគរបាលថ្នាក់ ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៤៤៤៦

០១-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៤៣៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ព្រះសង្ឃ និងសប្បុរសជន ចំនួន ២៣ អង្គ/ រូប ៤៤៤៧

០១-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៤៣៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ សប្បុរសជន ចំនួន ០៣ រូប ៤៤៤៨

០១-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៤៣៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន អាហ្គ្រោ អ៊ិនដាស្ត្រៀលផ្លេន និងសប្បុរសជន ចំនួន ១០ រូប ៤៤៤៩

០១-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៤៣៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ និងបុគ្គលិក នៃគណៈវិស្វករកម្ពុជា ចំនួន ០៨ រូប ៤៤៥០

០១-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៤៣៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ អភិបាលរងខេត្តពោធិ៍សាត់ ចំនួន ០៣ រូប ៤៤៥១

០១-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៤៣៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះ ព្រះសង្ឃ ចំនួន ០៥ អង្គ ៤៤៥២

០១-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៤៤០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ចំនួន ១០ រូប ៤៤៥៣

០២-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៤៤៥ ស្តីពី ការតែងតាំងមុខតំណែង ថ្នាក់ដឹកនាំធនាគារជាតិ នៃកម្ពុជា ចំនួន ០២ រូប ជាថ្មី ៤៤៥៤

II~រាជរដ្ឋាភិបាល

អនុក្រឹត្យ

២៦-៤-២០១៣ -អនុក្រឹត្យលេខ ២០៦ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ២.១៤៣,២៦ ហិកតា នៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ក្នុងនោះកាត់ចេញពីដីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព កាត់ចេញពីរមណីយដ្ឋានប្រាសាទព្រះវិហារ កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦៥៧ គ្រួសារ ៤៤៥៥

២៦-៤-២០១៣ -អនុក្រឹត្យលេខ ២០៧ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៨.០៧៨ ហិកតា នៅក្នុងស្រុករលាប្អៀរ ស្រុកទឹកផុស ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ក្នុងនោះកាត់ចេញពីដីអតីតសហគ្រាសសេរី កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនភាពីម៉ិច កាត់ចេញពីដីស្ថានីយ៍ម្សៅក្រដាស ហ៊ុន សែន មា-នក និងកាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង រក្សាមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៤៤៥៨

២៦-៤-២០១៣ -អនុក្រឹត្យលេខ ២០៨ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ១៤០ ហិកតា នៅស្រុកចិត្របុរី ខេត្តក្រចេះ ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គន ប៊ិញហ្វៀក (អេស ប៊ី ខេ) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ៣៦ គ្រួសារ ៤៤៦២

២៦-៤-២០១៣ -អនុក្រឹត្យលេខ ២០៩ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៥២៩ ហិកតា នៅស្រុកចិត្របុរី ខេត្តក្រចេះ ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គន ប៊ិញហ្វៀក (អេស ប៊ី ខេ) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ១៧៥ គ្រួសារ ៤៤៦៥

២៦-៤-២០១៣ -អនុក្រឹត្យលេខ ២១០ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ១៣៤ ហិកតា នៅស្រុកចិត្របុរី ខេត្តក្រចេះ ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គូន ប៊ិញហ្វឿក (អេស ប៊ី ខេ) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ៤៦ គ្រួសារ ៤៤៦៨
២៦-៤-២០១៣ -អនុក្រឹត្យលេខ ២១១ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ១.០០១ ហិកតា នៅស្រុកចិត្របុរី ខេត្តក្រចេះ ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហាមុនី ផ្លានថេសិន ខូអិលធីឌី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៦៨ គ្រួសារ ៤៤៧១
២៩-៤-២០១៣ -អនុក្រឹត្យលេខ ២១២ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ៤៤៧៤
២៩-៤-២០១៣ -អនុក្រឹត្យលេខ ២១៣ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ២.៤២៣ ហិកតា នៅស្រុក ស្ទឹងត្រង់ ខេត្តកំពង់ចាម ក្នុងនោះកាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងកាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន ធីម៉ាស៊ីរសួស លីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្ម ជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ និងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ៤៤៧៦
៣០-៤-២០១៣ -អនុក្រឹត្យលេខ ២១៤ អនក្រ.បក ស្តីពី ការចេញផ្សាយធនប័ត្រ ប្រភេទ ១០០.០០០ រៀល គំរូថ្មី ៤៤៧៩
៣០-៤-២០១៣ -អនុក្រឹត្យលេខ ២១៥ អនក្រ.បក ស្តីពី ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ៤៤៨០
០២-៥-២០១៣ -អនុក្រឹត្យលេខ ២១៦ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាសកម្មភាពជនពិការ ៤៤៨២
០២-៥-២០១៣ -អនុក្រឹត្យលេខ ២១៧ អនក្រ.បក ស្តីពី របបស្តីពីការសុំច្បាប់ និងការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទរបស់មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ៤៤៩៣
០៥-៣-២០១៣ -អនុក្រឹត្យលេខ ២៣៥ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមេដាយសហមេត្រី ៤៥០១
០៥-៣-២០១៣ -អនុក្រឹត្យលេខ ២៣៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៤៥០២
០៥-៣-២០១៣ -អនុក្រឹត្យលេខ ២៣៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៥០៣
០៥-៣-២០១៣ -អនុក្រឹត្យលេខ ២៣៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៥០៤
០៥-៣-២០១៣ -អនុក្រឹត្យលេខ ២៣៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៥០៥
០៥-៣-២០១៣ -អនុក្រឹត្យលេខ ២៤០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៥០៦

០៦-៣-២០១៣ -អនុក្រឹត្យលេខ ២៤១ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៥០៧
០៦-៣-២០១៣ -អនុក្រឹត្យលេខ ២៤២ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៤៥០៨
០៦-៣-២០១៣ -អនុក្រឹត្យលេខ ២៤៣ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៤៥០៩
០៦-៣-២០១៣ -អនុក្រឹត្យលេខ ២៤៤ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៥១០
០៦-៣-២០១៣ -អនុក្រឹត្យលេខ ២៤៥ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៤៥១២
០៦-៣-២០១៣ -អនុក្រឹត្យលេខ ២៤៦ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៤៥១៥
០៦-៣-២០១៣ -អនុក្រឹត្យលេខ ២៤៧ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៥១៦
០៦-៣-២០១៣ -អនុក្រឹត្យលេខ ២៤៨ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៤៥១៨
០៧-៣-២០១៣ -អនុក្រឹត្យលេខ ២៤៩ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៥២៥
០៧-៣-២០១៣ -អនុក្រឹត្យលេខ ២៥០ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៤៥២៦
០៧-៣-២០១៣ -អនុក្រឹត្យលេខ ២៥១ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៤៥២៨
០៧-៣-២០១៣ -អនុក្រឹត្យលេខ ២៥២ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៤៥៣០
០៧-៣-២០១៣ -អនុក្រឹត្យលេខ ២៥៣ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៤៥៤៩
០៧-៣-២០១៣ -អនុក្រឹត្យលេខ ២៥៤ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៥៦១
០៧-៣-២០១៣ -អនុក្រឹត្យលេខ ២៥៥ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៤៥៦២
០៧-៣-២០១៣ -អនុក្រឹត្យលេខ ២៥៦ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៤៥៦៤

ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៤៣០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សម្ភូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ ៖ ដំឡើងឋានន្តរស័ក្តិនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ៖

ក- ថ្នាក់ឧត្តមសេនីយ៍ឯក

- ឯកឧត្តមឧត្តមសេនីយ៍ទោ **ឱុច ណារ៉ុថ** អត្តលេខ ០៥០៧ ។

ខ- ថ្នាក់ឧត្តមសេនីយ៍ទោ

១- លោកស្រីឧត្តមសេនីយ៍ត្រី **ព្រំ ចន្ថា** អត្តលេខ ០២២១៣

២- លោកឧត្តមសេនីយ៍ត្រី **ឌឹម សារឿន** អត្តលេខ ០១៣៧៩ ។

មាត្រា ២ ៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ៖ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

រ.ល. ១៣០៥. ៤៣៥

លេខៈ ...០.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល
សួយ សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៣

ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៤៣១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ ៖ ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាតិជាន់ខ្ពស់ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១-	លោកវរសេនីយ៍ឯក	**កែវ**	**ម៊ុនសាខ**	អត្តលេខ ០២៧៦
២-	លោកវរសេនីយ៍ឯក	**សែត**	**វណ្ណាសិទ្ធិ**	អត្តលេខ ០៥២១១
៣-	លោកវរសេនីយ៍ឯក	**យ៉ាវ**	**សុធា**	អត្តលេខ ០០៩៩
៤-	លោកវរសេនីយ៍ឯក	**ខាត់**	**សាត**	អត្តលេខ ៦៨២៨៨
៥-	លោកវរសេនីយ៍ឯក	**ប៊ិន**	**មណីរដ្ឋ**	អត្តលេខ ៦៨៣២៩
៦-	លោកវរសេនីយ៍ឯក	**អ៊ុន**	**សុវណ្ណាសារ**	អត្តលេខ ៦៨៣២៨
៧-	លោកវរសេនីយ៍ឯក	**សុខ**	**គឹមស៊ីន**	អត្តលេខ ៦៨៣២៧
៨-	លោកស្រីវរសេនីយ៍ឯក	**ប៉ុណ្ណា**	**សំខាន់**	អត្តលេខ ១២២៩៥
៩-	លោកវរសេនីយ៍ឯក	**នូ**	**ឡឿន**	អត្តលេខ ០២១៨៧
១០-	លោកវរសេនីយ៍ឯក	**ឆូ**	**ឥន្ទីមា**	អត្តលេខ ០៣១៣២ ។

មាត្រា ២ ៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ៖ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧៧.១៣០៥.៤៣១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ២០១៣

លេខៈ ៤៧០ ច.ល

ដើម្បីចម្លងចែកចាយ

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៣

អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល

ស៊ិម សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៤៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **នាក់ ឌីឡែន** អត្តលេខ ០២២៦ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៧.១៣០៥.៤៣៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣

លេខៈ ៤៣៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣
អនុរដ្ឋលេខាធិការអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៤៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ព្រះសង្ឃ និងសប្បុរសជន ចំនួន ២៣ អង្គ/រូប ដែលបានបរិច្ចាគ កម្លាំងកាយ-ចិត្ត ព្រមទាំងធនធាន ផ្ទាល់ខ្លួន ចូលរួមជួយកសាង ព្រះវិហារវត្តមង្គលវង្ស ស្ថិតនៅក្នុងភូមិកណ្តាល ឃុំគរ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម

នូវ

ក-គ្រឿងឥស្សរិយយស ជាតូបការ

- លោកព្រឹទ្ធាចារ្យ អ៊ុន សារឿន

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

១-	ព្រះឧត្តមប្រឹយ៍ជា	អន ឆាងអាន	៥-	លោកស្រី	ហ៊ុង និកុល
២-	ឯកឧត្តម	សុក សាម	៦-	លោកស្រី	ទ៉ូច ពិសី
៣-	លោកជំទាវ	ម៉ក់ ឆៃលីម	៧-	លោក	សុផុន សំខាន់
៤-	លោកជំទាវ	ហ៊ុង និកា			

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

១-	ព្រះតេជគុណវិបុល្លត្ថេរ	ទេង ម៉េងគ្រី	៥-	លោក	ប៉ក់ គីមតៃ
២-	ព្រះភិក្ខុសុវណ្ណបញ្ញោ	អ៊ឹម សុភក្តិ	៦-	អ្នកស្រី	ជួង សារ៉ា
៣-	ព្រះអនុគណសុវណ្ណចន្ទត្ថេរ	ទ៉ាន់ ជាទី	៧-	លោក	ឆែម សំអាង
៤-	លោក	ឃុន សុវណ្ណរិទ្ធ			

ឃ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

១-	ព្រះតេជគុណចៅអធិការ	ខាត់ សំអេន	៥-	ឧបាសក	សាយ យឹម
២-	ឧបាសិកា	ស៊ីន គា	៦-	ឧបាសិកា	ម៉ក់ ឆៃឡេង
៣-	ឧបាសក	ទូន ចក	៧-	លោក	ម៉ក់ គីមជាន
៤-	ឧបាសិកា	ម៉ក់ លីអ៊ីង	៨-	លោក	តាំង ស្រីអេងណាំ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ ៤៣៤ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែឧសភា ឆ្នាំ២០១៣
អគ្គលេខា[illegible]រាជរដ្ឋាភិបាល

៣៣. ១៣០៥. ៤៣៩

សយ សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ២០១៣

ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៤៣៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០៣រូប ដែលបានបរិច្ចាគធនធាន ចូលរួមជួយកសាង ព្រះវិហារ ឧបដ្ឋានសាលា ផ្លូវលំ សាលារៀន ជួយឧបត្ថម្ភដល់ជនក្រីក្រ នៅតាមមូលដ្ឋាន នៃខេត្តព្រៃវែង និង ជួយកសាងសមិទ្ធផលនានាជាច្រើនទៀត នៅរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ធំ និងខេត្តកំពង់ចាម សម្រេចបានលទ្ធផលល្អប្រសើរ

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

១- អ្នកឧកញ៉ា ហ៊ុន តូ
២- ឧកញ៉ា ឡេង ហ៊ួរ
៣- ឯកឧត្តមឧកញ៉ា សុខ ផេង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.១៣០៥.៤៤០

លេខៈ ៤២៧ច.ល
ដើម្បីចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣

រាជធានីភ្នំពេញ ,ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៣
អគ្គលេខាធិការ រងទីស្តីការគណៈរដ្ឋមន្ត្រី

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៤៣៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រទានព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន អាហ្គ្រោ អ៊ិនដាស្ទ្រៀលផ្លេន និងសប្បុរសជន ចំនួន ១០រូប ដែលមានស្នាដៃល្អ ក្នុងការវិនិយោគលើដីសម្បទានសេដ្ឋកិច្ចដាំដំណាំកៅស៊ូ និងសាងសង់រោងចក្រកែច្នៃជ័រកៅស៊ូស្ងួតក្នុង ស្រុកសេសាន ខេត្តស្ទឹងត្រែង

នូវ

ក-គ្រឿងឥស្សរិយយស ជាគុបការ
- ១- ឯកឧត្តម ឧកញ៉ា ម៉ក់ គីមហុង
- ២- លោកជំទាវ ឆុយ រស្មី

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍
- ១- ឯកឧត្តម ម៉ែន សុភក្តិ
- ២- លោក សោម សុខហេង
- ៣- លោក នង ខាសនា
- ៤- លោក ហុង នីកូលីន

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ
- ១- លោក សុខ រិទ្ធី
- ២- លោក តាក ស៊ីថា
- ៣- លោក ជាន តារម្យ
- ៤- លោក ឡុង ចាន់ធី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ការ. ១៣០៥.៤៤១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៣

លេខ: ៤៣៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០១៣
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៤៣៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្នត្រ័យត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំ និងបុគ្គលិកនៃគណៈវិស្វករកម្ពុជា ចំនួន០៨រូប មានគុណបំណាច់
និងស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ កន្លងមក

នូវ

ក-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរត្ន ថ្នាក់ មហាសេរីវឌ្ឍន៍

១-លោកជំទាវ ហូ ណឿន
២-ឯកឧត្តម សុខុម ភគវន្តមុនី

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

ឯកឧត្តម ប្រាក់ មិន

គ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

១-ឯកឧត្តម សុទ្ធ សុបញ្ញា
២-ឯកឧត្តម លឹម សុផាវ
៣-ឯកឧត្តម សុខុម រិទ្ធីទុច
៤-ឯកឧត្តម កោ ជុំន
៥-ឯកឧត្តម សុខ សារ៉ន

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៧.១៣០៥.៤៤២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣

លេខៈ ៤៣១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៣
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៤៣៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

អភិបាលរងខេត្តពោធិសាត់ចំនួន ០៣រូប ដែលមានស្នាដៃល្អ
និងគុណបំណាច់ធំៗជាច្រើន ក្នុងការចូលរួមចំណែកកសាងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

គ្រឿងឥស្សរិយយស ជាតូបការ :

- លោក ម៉ក់ រ៉ា
- លោក អោក មុនី
- លោក សួន រិនឌី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.១៣០៥.៤៤៣

លេខ: ៤២៩ ច.ល

ដើម្បីចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៣
អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

សុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៤៣៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ប្រគេនចំពោះ

ព្រះសង្ឃ ចំនួន០៥អង្គ មានព្រះគុណបំណាច់ និងស្នាព្រះហស្តល្អ
ដែលបានខិតខំកៀរគរ ចលនាពុទ្ធបរិស័ទ និងបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាង
សមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា នៅតាមវត្តនានាទូទាំងស្រុកព្រះស្តេច ខេត្តព្រៃវែង

នូវ

ក-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

ព្រះតេជគុណមុនីរក្ខិតវង្សា ជា ទ៉ាន់នី

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

១-ព្រះតេជគុណចរិយាសោភ័ណ្ឌចិន្តមនោ សុខ ឆេង
២-ព្រះតេជគុណសតិសំវរោ អ៊ុំ នុន
៣-ព្រះតេជគុណសុធម្មលិខិតោ ស សុទត្ថិ
៤-ព្រះតេជគុណបញ្ញាវិសារទោ ទី រដ្ឋា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.១៣០៥.៤៤៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៣

លេខ: ៤៣០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៣
អគ្គលេខាធិការគណៈរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៤៤០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការនិងកងកម្លាំងប្រដាប់អាវុធ ចំនួន១០រូប មានស្នាដៃល្អនិងស្មារតីទទួលខុសត្រូវខ្ពស់
ក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ នៅខេត្តបន្ទាយមានជ័យ កន្លងមក

នូវ

ក-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

១-លោក បេ ឡឹគីម
២-លោក លី ស្រួយ

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ

១-លោកស្រី ប៉ុក ណារី
២-វរសេនីយ៍ត្រី រស់ សំបូរ អត្តលេខ ១៤៥៣២១
៣-អនុសេនីយ៍ឯក ខួន គិរម្យ អត្តលេខ ០៣៦៣១៧
៤-លោក ហ្វាង ឌុន
៥-លោក អ៊ុំ ចណ្ណម៉ៅ
៦-លោកស្រី ហែម គឹមថុន
៧-លោក ឈាង ង៉ែ
៨-លោកវេជ្ជបណ្ឌិត គួច ចាន់ថន

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧. ១៣០៥. ៤៤៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៣

លេខៈ ៤៣៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៣
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៤៤៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៩ និង ៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: តែងតាំងមុខតំណែងថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាចំនួន ២ រូប ជាថ្មី ៖

១- លោកជំទាវ **នាង ច័ន្ទថាណា** ជាអគ្គទេសាភិបាលរងធនាគារជាតិនៃកម្ពុជា
មានឋានៈស្មើ **រដ្ឋមន្ត្រី**

២- លោកជំទាវ **អ៊ុក ម៉ាលី** ជាអគ្គទេសាភិបាលរងធនាគារជាតិនៃកម្ពុជា
មានឋានៈស្មើ **រដ្ឋមន្ត្រី** ។

មាត្រា ២: បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល. ១៣០៥.៤៥០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៣

លេខ: ៤៣៧ ច.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ស៊យ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២០៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីសរុបទំហំ ២.១៤៣,២៦ ហិកតា នៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ក្នុងនោះ កាត់ចេញពីដីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព កាត់ចេញពីរមណីយដ្ឋានប្រាសាទព្រះវិហារ កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦៥៧ គ្រួសារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤១៣/៤០៥ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សា គោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយ ខុសច្បាប់
- លិខិតលេខ ០២៩ គ.គ្រ.ដ.រ.ខ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រង ដីរដ្ឋ ខេត្តព្រះវិហារ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ២.១៤៣,២៦ ហិកតា ក្នុងនោះ (១) ទំហំ ៨៥០,៧៦ ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព និងទំហំ ០៧ ហិកតា កាត់ចេញពីរមណីយដ្ឋាន ប្រាសាទព្រះវិហារ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៤១៣/៤០៥ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ និង (២) ទំហំ ១.២៨៥,៥០ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើ អនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ភូមិស្រអែម ខាងត្បូង ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដែលរួមមាន ៖

- ផ្ទៃដីទំហំ ៨៥០,៧៦ ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ។
- ផ្ទៃដីទំហំ ០៧ ហិកតា កាត់ចេញពីរមណីយដ្ឋានប្រាសាទព្រះវិហារ សម្រាប់ធ្វើ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ។
- ផ្ទៃដីទំហំ ១.២៨៥,៥០ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ សម្រាប់ធ្វើ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ។

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាម កាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ៦៥៧ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ភូមិស្រអែមខាងត្បូង ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដែលរួមមាន ៖

- ផ្ទៃដីកាត់ចេញពីដីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៥១ គ្រួសារ ។
- ផ្ទៃដីកាត់ចេញពីរមណីយដ្ឋានប្រាសាទព្រះវិហារ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ១៦ គ្រួសារ ។
- ផ្ទៃដីកាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៩០ គ្រួសារ ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧០៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី

ការកាត់ដីសរុបទំហំ ៨.០៧៨ ហិកតា នៅក្នុងស្រុករលាប្អៀរ ស្រុកទឹកផុស ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ក្នុងនោះ កាត់ចេញពីដីអតីតសហគ្រាសសេរី កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន គាពីម៉ិច កាត់ចេញពីដីស្ថានីយ៍ស្រាវជ្រាវ ក្រុងជាស ហ៊ីន សែន មា-នក និងកាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៣៣៣ លស ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តកំពង់ឆ្នាំង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ៨.០៧៨ ហិកតា ក្នុងនោះ (១) ទំហំ **៣៣៩ ហិកតា** កាត់ចេញពីដីអតីតសហគ្រាសសេរី (២) ទំហំ **៥.៤០០ ហិកតា** កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច (៣) ទំហំ **២.០៤៥ ហិកតា** កាត់ចេញពីដីស្ថានីយ៍ម្សៅក្រដាស ហ៊ុន សែន មា-នក និង (៤) ទំហំ **២៩៤ ហិកតា** កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ **៧.៥៩៨ ហិកតា** ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ **៤៨០ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិសាស្ត្រដូចខាងក្រោម៖

១.ឃុំពង្រ ស្រុករលាប្អៀរ

- ផ្ទៃដីទំហំ **៧៧** ហិកតា កាត់ចេញពីដីអតីតសហគ្រាសសេរី សម្រាប់ប្រទានកម្មទំហំ **៧១** ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ **០៦** ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ **នៅភូមិអណ្តូងពោធិ៍** ។

២.ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ

- ផ្ទៃដីទំហំ ២៦២ ហិកតា កាត់ចេញពីដីអតីតសហគ្រាសសេរី សម្រាប់ប្រទានកម្មទំហំ ២៥២ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១០ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិឧទុម្ពរ ។

៣.ឃុំក្បាលទឹក ស្រុកទឹកផុស

- កាត់ផ្ទៃដីសរុបទំហំ ១.៦៨៩ ហិកតា ក្នុងនោះ (១)ទំហំ ១.៣៩៥ កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច និង(២) ទំហំ ២៩៤ ហិកតា កាត់ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ សម្រាប់ប្រទានកម្មទំហំ ១.៦១២ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៧៧ ហិកតា រក្សាទុកជាដីបម្រុងផ្សេងៗ នៅភូមិថ្នល់កែង ។

៤.ឃុំក្រាំងស្គារ ស្រុកទឹកផុស

- ផ្ទៃដីទំហំ ៣.៦៦៧ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ប្រទានកម្មទំហំ ៣.៤២៦ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២៤១ ហិកតា រក្សាទុកជាដីបម្រុងផ្សេងៗ នៅភូមិអូរល្ពៅ ។

៥.ឃុំចោងម៉ោង ស្រុកទឹកផុស

- ផ្ទៃដីទំហំ ៣៣៨ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ប្រទានកម្មទំហំ ៣២៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ០៩ ហិកតា រក្សាទុកជាដីបម្រុងផ្សេងៗ នៅភូមិស្វាយចេក ។

៦.ឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ

- ផ្ទៃដីទំហំ ២.០៤៥ ហិកតា កាត់ចេញពីដីស្ថានីយ៍ម្សៅក្រដាស ហ៊ុន សែន មា-នក សម្រាប់ប្រទានកម្មទំហំ ១.៩០៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៣៧ ហិកតា រក្សាទុកជាដីបម្រុងផ្សេងៗ នៅភូមិស្រែសារ ។

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ៣.០៦៩ គ្រួសារ នៅខេត្តពោធិ៍សាត់ ដែលស្ថិតនៅក្នុងភូមិសាស្ត្រដូចខាងក្រោម៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៧៦ គ្រួសារ នៅភូមិអណ្តូងពោធិ៍ ឃុំពង្រ ស្រុកលោហៀរ ។
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៩៨ គ្រួសារ នៅភូមិឧទុម្ពរ ឃុំស្វាយជ្រុំ ស្រុកលោហៀរ។
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥៩១ គ្រួសារ នៅភូមិថ្នល់កែង ឃុំក្បាលទឹក ស្រុកទឹកផុស។

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦៨៩ គ្រួសារ និងទំហំ ២៥១ ហិកតា រក្សាទុកជាដីបម្រុងផ្សេងៗ នៅភូមិអូរល្ពៅ ឃុំក្រាំងស្គារ ស្រុកទឹកផុស ។
- ប្រទានកម្មទំហំ ៣២៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨០០ គ្រួសារ និងទំហំ ៩ ហិកតា រក្សាទុកជាដីបម្រុងផ្សេងៗ នៅភូមិស្វាយចេក ឃុំចោងម៉ោង ស្រុកទឹកផុស។
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦២០ គ្រួសារ នៅភូមិស្រែសារ ឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ[illegible] ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២០៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំ ១៤០ ហិកតា នៅស្រុកចិត្របុរី ខេត្តក្រចេះ ចេញពីដីសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុន ដូទីសាយហ្គន ប៊ិញហ្វឿក (អេស ប៊ី ខេ) និងធ្វើអនុបយោគជាដីឯកជន របស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៦ គ្រួសារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិត ២៥៦ ល.ក្រចចុះថ្ងៃទី ១៩ ខែមេសាឆ្នាំ ២០១៣របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ផ្ទៃដីទំហំ ១៩០ ហិកតា ចេញពីដីសម្បទាន សេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គូន ប៊ិញហ្វៀក (អេស ប៊ី ខេ) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៦ គ្រួសារ នៅភូមិស្វាយជ្រុំ ឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ នៅភូមិស្វាយជ្រុំ ឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤..

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមេសា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២០៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំ ៥២៩ ហិកតា នៅស្រុកចិត្របុរី ខេត្តក្រចេះ ចេញពីដីសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុន ដូធីសាយហ្គន ប៊ិញហឿក (អេស ប៊ី ខេ) និងធ្វើអនុបយោគជាដីឯកជន របស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៧៥ គ្រួសារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិត ២៥៣ ល.ក្រចចុះថ្ងៃទី ១៩ ខែមេសាឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ផ្ទៃដីទំហំ ៥២៩ ហិកតា ចេញពីដីសម្បទាន សេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទឹសាយហ្គុន ប៊ិញហ្វឿក (អេស ប៊ី ខេ) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៧៥ គ្រួសារ នៅភូមិអាលច ឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ នៅភូមិអាលច ឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ ។

មាត្រា ៣ .-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧២០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំ ១៣៤ ហិកតា នៅស្រុកចិត្របុរី ខេត្តក្រចេះ ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូឌីសាយហ្គន ប៊ិញហឿក (អេស ប៊ី ខេ) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៦ គ្រួសារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិត ២៥៥ ឈក្រចចុះថ្ងៃទី ១៩ ខែមេសាឆ្នាំ ២០១៣របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ផ្ទៃដីទំហំ ១៣៩ ហិកតា ចេញពីដីសម្បទាន សេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គូន ប៊ិញហ្វឿក (អេស ប៊ី ខេ) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨៦ គ្រួសារ នៅភូមិម្កៀរ ឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ នៅភូមិម្កៀរ ឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ០៣ ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២១ អនក្រ-បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំ ១.០០១ ហិកតា នៅស្រុកចិត្របុរី ខេត្តក្រចេះ ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហាមុនី ផ្លានថេសិន ខូ អិលធីឌី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៦៨ គ្រួសារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិត ២៥៩ លក្រច ចុះថ្ងៃទី ១៩ ខែមេសាឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ផ្ទៃដីទំហំ ១.០០១ ហិកតា ចេញពីដីសម្បទាន សេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហាមុនីផ្លានថេសិន ខូ អិលធីឌី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៦៨ គ្រួសារ នៅភូមិកសាង ឃុំចង្រ្កង់ ស្រុកចិត្របុរី ខេត្តក្រចេះ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ នៅភូមិកសាង ឃុំចង្រ្កង់ ស្រុកចិត្របុរី ខេត្តក្រចេះ ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២១២ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ឬចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែល ប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
